ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ៥១៤ ក្រ២ "វ"

-ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៨

-សំណុំរឿងព្រហ្មទណ្ឌលេខ ៦៤៤៨
ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៧

-សំណុំរឿងស៊ើបសួរលេខ ៣៩៤៤
ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧

-សំណុំរឿងជំនុំជម្រះលេខ ៧៥០
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង ២ និង ៣០ នាទី រសៀល នៅសាលសវនាការទី២ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកអនុប្រធាន [redacted] ជាប្រធានក្រុមប្រឹក្សា

-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦៤៤៨ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៧ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] **ស្រីណែត** ហៅ ដា ភេទស្រី អាយុ ២៧ឆ្នាំជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី ៦ មុខរបរ អ្នករាប់លុយ ទីកន្លែងកំណើត សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ អាស័យដ្ឋានបច្ចុប្បន្ននៅ [redacted] ច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ប្តីឈ្មោះ [redacted] (លែងលះ) មានកូន ០២នាក់ ទោសពីមុន គ្មាន ។

ឃាត់ខ្លួនថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៧

ឃុំខ្លួនថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៧

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

២. ឈ្មោះ [redacted] **ពិសិដ្ឋ** ហៅ សិដ្ឋ ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៥ មុខរបរ លក់ឪស ទីកន្លែងកំណើត ខេត្តព្រៃវែង អាស័យដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ

Scanned with CamScanner

២៩ ផ្ទ[redacted] ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ[redacted]"រស់" នៅលីវ ទោសពីមុន គ្មាន ។

ឃាត់ខ្លួនថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៧

ឃុំខ្លួនថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៧

លោក [redacted] **សុខា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

៣. ឈ្មោះ [redacted] **បញ្ញា** ហៅ **ឡា រី មិះ** ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌គ្មាន មុខរបរ ជាងសាក់ ទីកន្លែងកំណើតផ្សារលើ ក្រុងកំពុងសោម អាស័យដ្ឋាន[redacted] ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" នៅលីវ ទោសពីមុន គ្មាន ។

ឃាត់ខ្លួនថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៧

ឃុំខ្លួនថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៧

លោក [redacted] **សុខា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ខុនដូរលេខ១២៥(បន្ទប់លេខ៥២) ផ្លូវលេខ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល១៦ និង១០នាទី ដោយមានការដឹកនាំសម្របសម្រួលពីតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ កម្លាំងជំនាញការិយាល័យប្រឆាំងជំនួញគ្រឿងញៀនខុសច្បាប់ នៃមន្ទីរប្រឆាំងគ្រឿងញៀនបានចុះអនុវត្តវិធានប្រគល់ដោយមានការឃ្លាំមើល ឬញុះញង់ឱ្យលក់គ្រឿងញៀនខុសច្បាប់ និងបានបង្ក្រាបនៅចំពេលមុខសញ្ញា កំពុងធ្វើសកម្មភាពនៅចំណុចខុនដូរលេខ១២៥(បន្ទប់៥២) ផ្លូវលេខ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនជនសង្ស័យចំនួន១នាក់ឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ ២៧ឆ្នាំជនជាតិខ្មែរ និងចាប់យកវត្ថុតាង សារធាតុញៀន ប្រភេទមេតំហ្វេតាមីន (ICE) ទម្ងន់៣,៦៣ក្រាម ហើយភ្លាមៗនោះ យើងបាននាំខ្លួនជនសង្ស័យរូបនេះទៅចង្អុលបង្ហាញបន្ទប់(បន្ទប់ខុនដូរលេខ៥២) របស់មេខ្លោង និងជាម្ចាស់សារធាតុញៀន និងបានឆែកឆេររកឃើញ សារធាតុញៀនប្រភេទមេតំហ្វេតាមីន (ICE) ទម្ងន់៤៩៥,៥០ក្រាម ដោយឃាត់បានជនសង្ស័យចំនួន ២នាក់មានឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ ២៣ឆ្នាំជនជាតិខ្មែរ និងឈ្មោះ [redacted] បញ្ញា ភេទប្រុស អាយុ ១៧ឆ្នាំ ផ្សេងទៀត ហើយកសាងសំណុំរឿងបញ្ជូនជនសង្ស័យ និងវត្ថុតាង មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។ (តាមលទ្ធផលកោសលវិច័យលើសារធាតុញៀន



Scanned with CamScanner

កម្រិតភាពសុទ្ធ សរុប ៣៧៤.៣៥ % នៃទម្ងន់សរុប ជារបស់ឈ្មោះ [redacted] ពិសិដ្ឋ និង កម្រិតភាពសុទ្ធ សរុប ២.៦៨% នៃទម្ងន់សរុប ជារបស់ឈ្មោះ [redacted] ស្រីណែត) ។

-បានឃើញ របាយការណ៍សំយោគលេខ ៩៤៧ រ.ប.ក ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៧ របស់មន្ទីរប្រឆាំងគ្រឿងញៀន ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៩៧២ អ.យ.ដ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៦០២ អ.យ.ដ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៨៣៣ “ង” ជ.ដ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## **នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] **ស្រីណែត** បានឆ្លើយថា កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង៤និង១០នាទីមានបុរសម្នាក់បានទូរសព្ទមកខ្លួន ថាចង់ទិញអីវ៉ាន់ចំនួន១ជី ពេលនោះខ្លួនបានឆ្លើយថាចាំសួរគេឱ្យក្រោយមកខ្លួនក៏បានប្រាប់ម្នាក់នោះថាមានឥវ៉ាន់(ថ្នាំញៀន) ឱ្យយកលុយមកឱ្យខ្លួន កន្លះម៉ោងបានបុរសម្នាក់នោះយកលុយមកឱ្យ ខ្លួនក៏បានយកលុយពីបុរសម្នាក់នោះយកទៅឱ្យមនុស្សដែលនៅមុខបន្ទប់លេខ៥២ ស្ទុកទៅក្នុងបន្ទប់នោះបានហុចថ្នាំញៀនមកឱ្យក្រោមប្រឡោះទ្វារ។ បានថ្នាំញៀនហើយខ្លួនក៏យកទៅឱ្យបុរសម្នាក់ ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។ បន្ទាប់មកសមត្ថកិច្ចបានឱ្យខ្លួនជូនទៅរកនៅបន្ទប់លេខ៥២ ឃាត់ខ្លួនបានមនុស្ស២នាក់ ថ្នាំញៀន និងប្រដាប់ប្រដាជក់គ្រឿងញៀន ។ ខ្លួនរកស៊ីទើបតែលើកទី១នោះទេ ។ លក់១ដងខ្លួនចំណេញបានប្រាក់ចំនួន២០(ម្ភៃ)ដុល្លាអាមេរិក ។ ថ្នាំញៀនគឺខ្លួនទិញពីអ្នកលក់នៅក្នុងបន្ទប់លេខ៥២នៃខុនដូរលេខ១២៥ ផ្លូវលេខ៤៤បេ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ នៅថ្ងៃនោះខ្លួនទិញថ្នាំញៀននៅបន្ទប់លេខ៥២ តម្លៃ ១០០(មួយរយ)ដុល្លាអាមេរិក ពេលខ្លួនទិញខ្លួនទូរសព្ទទៅរកគេប្រាប់ថាទៅយកឥវ៉ាន់ ពេលដល់បន្ទប់ខ្លួនគោះទ្វារបន្ទប់ហើយអ្នកនៅក្នុងបន្ទប់គេបង្ហើបទ្វារបន្តិចប្រគល់គ្រឿងញៀនឱ្យខ្លួន ហើយខ្លួនប្រគល់លុយឱ្យគេ ។ ខ្លួនស្គាល់លេខទូរសព្ទអ្នកលក់គ្រឿងញៀននេះតាមរយៈមិត្តភក្តិខ្លួន ។ ខ្លួនអត់ចេះប្រើប្រាស់គ្រឿងញៀនទេ ។

-តាមអំណានកំណត់ហេតុស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ស្រីណែត** ឆ្លើយនៅមន្ទីរប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ថា បានជាសមត្ថកិច្ចឃាត់ខ្លួនមកកាន់ទីនេះ



Scanned with CamScanner

ពីព្រោះខ្លួនបានប្រព្រឹត្តសកម្មភាពជួញដូរគ្រឿងញៀនខុសច្បាប់ ។ ខ្លួនសូមឆ្លើយសារភាពចំពោះមុខសមត្ថកិច្ចថាខ្លួនចេះប្រើប្រាស់គ្រឿងញៀននៅក្នុងខែមីនា ឆ្នាំ២០១៧ តាមរយៈមិត្តភក្តិដោយពេលនោះខ្លួនពិបាកចិត្តឈ្លោះគ្នាជាមួយប្តី រហូតឈានដល់ការលែងលះគ្នា។ គ្រឿងញៀនដែលខ្លួនប្រើប្រាស់គឺខ្លួនទិញពីឈ្មោះ សិទ្ធ ភេទប្រុស ស្នាក់នៅបន្ទប់លេខ៥២ ដែលជាអ្នករកស៊ីជួញដូរគ្រឿងញៀនខុសច្បាប់ បន្ទាប់មកនៅថ្ងៃទី ៨ ខែតុលា ឆ្នាំ២០១៧ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ សិទ្ធ ចំនួន១០ម៉ឺនរៀល ដើម្បីយកមកវែកលក់បន្ត។ ក្នុងគ្រឿងញៀនតម្លៃ១០ម៉ឺនរៀល ខ្លួនបានចំណេញ ៦ម៉ឺនរៀល ។ ជាក់ស្តែងនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១៥ជាង មានគេទូរសព្ទមកខ្លួនរកទិញគ្រឿងញៀនចំនួន ១ជី ពេលនោះខ្លួនបានប្រាប់ទៅគេវិញថា ចាំខ្លួនសួរគេ(សិទ្ធ)សិន បន្ទាប់មកខ្លួនបានមកបន្ទប់របស់ឈ្មោះ សិទ្ធ ដើម្បីសួររកទិញថ្នាំញៀនតាមចំនួនដែលម៉ូយកម្ម៉ង់ទិញ ពេលនោះឈ្មោះសិទ្ធ សួរខ្លួនថា ម៉េចបានខ្លួនទិញច្រើនម្ល៉េះ ពីព្រោះខ្លួនមិនសូវមានលុយ ហើយធ្លាប់ទិញពីគេ(សិទ្ធ)តែ១០ម៉ឺនរៀល ខ្លួនប្រាប់ឈ្មោះ សិទ្ធ ថា មានម៉ូយរបស់ខ្លួនត្រូវការទិញ ឈ្មោះ សិទ្ធ សួរខ្លួនថា តើស្គាល់គេច្បាស់ រឺ អត់ ខ្លួនប្រាប់វិញថា ស្គាល់ច្បាស់ទើបឈ្មោះ សិទ្ធ ព្រមលក់ឲ្យក្នុង១ជី តម្លៃ ១២០ដុល្លាអាមេរិក ហើយខ្លួនបានសុំឲ្យគេគិតតែ ១០០ដុល្លាអាមេរិក បានហើយ ទុកឲ្យខ្លួនបាន ២០ ដុល្លាផង ឈ្មោះ សិទ្ធ ក៏យល់ព្រម។ លុះដល់វេលាម៉ោងប្រហែល១៦ និង៣០នាទី ខណៈពេលដែលខ្លួនកំពុងដោះដូរថ្នាំញៀនជាម៉ូយ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន រួមជាម៉ូយ វត្ថុតាងថ្នាំញៀន តែម្តង។ បក្ខពួករបស់ខ្លួនរួមមាន៖ ឈ្មោះ សិទ្ធ ភេទប្រុស ជនជាតិខ្មែរ (ត្រូវបានឃាត់ខ្លួន) និង រូបខ្លួន ។

-ជនជាប់ចោទឈ្មោះ [redacted] **ពិសិដ្ឋ** បានឆ្លើយថា កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង១ជាង ឈ្មោះ ពាវ បានទូរសព្ទមកខ្លួនតាមរយៈលេខ០១០ ៣២៤ ៥៦៧ មកឲ្យខ្លួនមកយកអាវរបស់គាត់នៅវត្តដំបូកខ្ពស់ក្បែរធុងសំរាម។ ក្រោយមកបានប្រហែលជា១៥នាទី ខ្លួនក៏បានទៅកន្លែងអ្វីដែលគាត់ប្រាប់ក៏បានឃើញខោអាវដូចដែលគាត់បានប្រាប់តាមទូរសព្ទ។ ខ្លួនក៏បានយកអាវនោះមកខុនដូរ១២៥ ផ្លូវលេខ៤៤បេ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ បន្ទប់លេខ៥២ ។ ខ្លួនមិនបានស្រាយអាវនោះមើលទេ នៅក្នុងបន្ទប់ខុនដូរបានគ្នា៤នាក់ ។ ខ្លួនចូលក្នុងបន្ទប់ខុនដូរនោះប្រហែលជា ១ម៉ោង ស្រប់តែមានប៉ូលីសសំរុកចូលក្នុងបន្ទប់ឃាត់រូបខ្លួន និងឈ្មោះ [redacted] បញ្ញា ,ឈ្មោះ សម្បត្តិ ចំពោះឈ្មោះ តី បានរត់ចេញគេចខ្លួនបាត់ ។ ខ្លួនរកស៊ីជួញដូរគ្រឿងញៀនរយៈពេលបានប្រហែលជាមួយខែមកហើយ ។ ថ្នាំញៀនយកមកលក់គឺយកពីហាពាវ និងហាបុង ជាមនុស្សតែម្នាក់។ ក្នុង១ថ្ងៃខ្លួនលក់ថ្នាំញៀនអស់ចំនួន ១ជីបានចំនួន ១០០ដុល្លា ចំណេញបានប្រាក់ចំនួន ២០ដុល្លា ។ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបានថ្នាំញៀនចំនួន ១កូនថង់របស់ខ្លួន ចំណែក៤កញ្ចប់ផ្សេងទៀត នៅក្នុងអាវ ពុំបានដឹងនោះទេ។ ក្រៅពីថ្នាំញៀនមានឧបករណ៍សម្រាប់ជក់ផ្សេងទៀត។ សមត្ថកិច្ចបានចុះបង្ក្រាបដកហូតទូរសព្ទដៃរបស់ខ្លួនចំនួន ៣គ្រឿង៖ ១.សេរេនភ្លើស ពណ៌ខ្មៅ, ២.



Scanned with CamScanner

ស៊ិចភ្លើស ពណ៌ទឹកមាស, ៣.ស៊ីច ពណ៌ទឹកមាស, ៤.លុយដុល្លាចំនួន ៨០០ដុល្លា និងលុយខ្មែរចំនួន ២០០០០០០(ពីរលាន)រៀល ,ម៉ូតូ១គ្រឿងម៉ាកនិច ពណ៌ខ្មៅលាយក្រហមសេរីឆ្នាំ២០១៤ ពាក់ស្លាកលេខ ២០៨៩ ភ្នំពេញ១DJ ។ ចំណែកទូរសព្ទ័ម៉ាកសេវេនភ្លើសពណ៌ខ្មៅ ,ទូរសព្ទ៣ម៉ាស៊ីនពណ៌ទឹកមាស ជារបស់ប្អូន និងម្តាយរបស់ខ្លួនដែលគាត់ឲ្យយកទៅមើលថ្ម ចំណែកលុយដែលសមត្ថកិច្ចដកហូតនោះ គឺជាលុយម្តាយរបស់ខ្លួនឲ្យយកទៅបង់ រៀនទូរសព្ទ័៨០០ដុល្លា ។

-តាមអំណានកំណត់ហេតុស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ពិសិដ្ឋ** ឆ្លើយនៅមន្ទីរប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ថា បានជាសមត្ថកិច្ចឃាត់ខ្លួនមកកាន់ទីនេះពីព្រោះខ្លួនប្រព្រឹត្តសកម្មភាពរកស៊ីលក់ដូរថ្នាំញៀនខុសច្បាប់ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ។ ខ្លួនសូមឆ្លើយសារភាពចំពោះមុខសមត្ថកិច្ចថាខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយៈពេលប្រហែល ១ឆ្នាំមកហើយគឺជក់គ្រឿងញៀនទឹកកកដែលទិញពីក្មេងៗ នៅមុខក្លាន់ពីរនៅមុខស្ពានច្បារក្រសួងការពារជាតិ នៅអំឡុងខែសីហា ឆ្នាំ២០១៧ ខ្លួនបានស្គាល់ឈ្មោះ ហុង ភេទប្រុស នៅក្នុងបន្ទប់ខារ៉ាអូខេ ឡាហ្វេហ្គាស់ ផ្លូវ២៧១ ។ ពេលនោះឈ្មោះ ហុង បានណែនាំខ្លួនឲ្យចេះរកស៊ីថ្នាំញៀន ហើយបានប្រគល់ថ្នាំញៀនចំនួន ១ជី មកឲ្យខ្លួនហើយប្រាប់ថា ពេលលក់អស់វេលុយឲ្យទៅគេ(ហុង) ចំនួន ៨០ដុល្លា។ ឈ្មោះ ហុង បានប្រគល់ថ្នាំញៀនទឹកកកចំនួនមួយៗ ប្រាំលើក ទើបឡើងដល់កន្លះជ្រុង តម្លៃ៣៥០ដុល្លា ។ ពេលខ្លួនយកមកវ៉ែលកលក់ចេញ បានតម្លៃជាង ៦០០ដុល្លាអាមេរិក ។នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ឈ្មោះ ហុង បានទូរសព្ទ័មកប្រាប់ខ្លួនឲ្យទៅយកថ្នាំញៀននៅក្បែរផុងសំរាម ដែលនៅតាមផ្លូវចូលវត្តដំបូកខ្ពស់។ ពេលទៅដល់ផុងសំរាមខ្លួនបានឃើញនិងយកថ្នាំញៀនមកដល់បន្ទប់ក៏បើកមើលឃើញថ្នាំញៀនទឹកកកចំនួន៥ថង់ ក្នុងមួយថង់ៗទម្ងន់១ខាំ ហើយខ្លួនបើកយកមួយថង់មកវ៉ែលកច្រកចូលថង់តូចៗចំនួន ១ជ្រុង។ ហើយបានទូរសព្ទ័ទៅសួរឈ្មោះ ហុង ថាច្រើនម្ល៉េះ។ ពេលនោះឈ្មោះ ហុង ប្រាប់ថាចាំយកឲ្យម៉ូយគាត់ផង ចំនួន ៤ថង់ នៅពេលគេ(ម៉ូយ) ទូរសព្ទ័មកខ្លួន។ រហូតដល់ម៉ោង៤ ថ្ងៃដដែលនេះ ស្រាប់តែមានគេមកគោះទ្វារ ខ្លួនក៏បើកទ្វារស្រាប់តែឃើញសមត្ថកិច្ច ពួកខ្លួនក៏រត់ទៅក្រោយ ហើយឈ្មោះ ប៊ិះ(សេងបញ្ញា) បាយកថ្នាំញៀន៤ថង់នោះគប់ទៅក្រោមចូលទៅក្នុងផ្ទះប្រជាជន។ បន្ទាប់មកពួកខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួនជាមួយថ្នាំញៀនមួយខាំ។ ក្រោយមកសមត្ថកិច្ចបានទៅយកថ្នាំញៀនដែលគប់ចោលនោះមកវិញ។ ចំពោះជញ្ជីងថ្លឹងថ្នាំញៀនចំនួន២នោះ គឺឈ្មោះ ហុង ដាក់ក្នុងកញ្ចប់ថ្នាំញៀនចំនួន១ ហើយមួយទៀតជារបស់ឈ្មោះ ណែត ជាអ្នកយកមកឲ្យសម្រាប់ថ្លឹងថ្នាំញៀន។ រីឯឈ្មោះ ឡុង, រិទ្ធ ,សម្បត្តិ គឺពុំដែលពាក់ពន្ធ័ក្នុងករណីជួញដូរថ្នាំញៀនទេ គ្រាន់ធ្លាប់មកទិញជក់តែប៉ុណ្ណោះ។ នៅពេលខ្លួនជួញដូរថ្នាំញៀនខាងលើមានបក្ខពួកដូចខាងក្រោម៖

១.ឈ្មោះ ប៊ិះ ([redacted]បញ្ញា) ឃាត់ខ្លួន



Scanned with CamScanner

២.ឈ្មោះ ហុង ភេទប្រុស អាយុ ជាង២០ឆ្នាំ ជនជាតិខ្មែរ ទីលំនៅពុំពិតប្រាកដ កាន់ទូរសព្ទ ០១០ ៣២៤៥៦៧ ដែលមានភិនភាគដូចខាងក្រោម៖

មាឌធំ កំពស់មួយម៉ែត្រចិត្តសិប សម្បុរស សក់ស្កូត ច្រមុះស្រួច ។

-ជនជាប់ចោទឈ្មោះ [redacted] **បញ្ញា** បានឆ្លើយថា កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១២ថ្ងៃត្រង់ ខ្លួនចុះទៅទិញបាយពេលឡើងមកវិញក៏បានឃើញឈ្មោះ តី ,ឈ្មោះ សិទ្ធ និងឈ្មោះ បាក់ កំពុងជក់គ្រឿងញៀននៅក្នុងបន្ទប់ ខ្លួនក៏បានហូបបាយហើយក៏ជក់ថ្នាំញៀនជាមួយគ្នា។ នៅក្នុងបន្ទប់ខុនដូរលេខ ៥២ មានគ្នាចំនួន ៤នាក់ ខ្លួនមកបន្ទប់ខុនដូរនេះរយៈពេល៣ថ្ងៃមកហើយ ខ្លួនគ្មានផ្ទះទេ ពីមុននៅជាមួយសង្សា។ ក្រោយពេលពួកខ្លួនជក់ថ្នាំញៀនរួចហើយខ្លួនបំរុងចុះទៅក្រោមវិញ ឈ្មោះ តី បានប្រាប់ខ្លួនថា ផ្ញើខោអាវឲ្យឈ្មោះ ពាវ ខ្លួនក៏ទទួលចំណែកឈ្មោះ តី ទៅបើកទូពេលនោះសមត្ថកិច្ចក៏បុកចូលតែម្តង ឃាត់រូបខ្លួន, សម្បត្តិ, សិទ្ធ ។ ខ្លួនមិនបានជួញដូរគ្រឿងញៀនទេ ខ្លួនទទួលស្គាល់ថា ខ្លួនប្រើប្រាស់គ្រឿងញៀន ។ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតថ្នាំញៀន ចំនួន៤កញ្ចប់ពីឈ្មោះ [redacted] ពិសិដ្ឋ ចំណែកថ្នាំញៀន ៤កញ្ចប់ទៀត គឺជារបស់ឈ្មោះ តី ។ ហើយដកហូតលុយខ្លួនចំនួន ៤០០០រៀល ទូរសព្ទ១២៨០មួយគ្រឿង ។ ចំណែកឈ្មោះ [redacted] ពិសិដ្ឋ សមត្ថកិច្ចដកហូតទូរសព្ទចំនួន ៣គ្រឿង លុយមួយចំនួន មាន លុយដុល្លា និងលុយខ្មែរ ប៉ុន្តែពុំដឹងថាមានចំនួនប៉ុន្មានទេ។ ម៉ូតូ១គ្រឿងម៉ាកនិក។

-តាមអំណានកំណត់ហេតុស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **បញ្ញា** ឆ្លើយនៅមន្ទីរប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ថា បានជាសមត្ថកិច្ចឃាត់ខ្លួនមកកាន់ទីនេះពីព្រោះខ្លួនប្រព្រឹត្តសកម្មភាពប្រើប្រាស់ថ្នាំញៀន និងបានកាន់យកស្បោងដាក់សំលៀកបំពាក់ដែលមានលាក់ទុកគ្រឿងញៀនខាងក្នុងទៅឲ្យគេ តាមបញ្ជើរបស់ឈ្មោះ សិទ្ធ ។ ខ្លួនសូមសារភាពចំពោះមុខសមត្ថកិច្ចថា ខ្លួនពិតជាបានធ្វើសកម្មភាពខាងលើពិតប្រាកដមែន ដោយបានស្គាល់ឈ្មោះ សិទ្ធ([redacted] ពិសិទ្ធ) តាំងពីឆ្នាំ២០០៩មកម្លេះ ដោយធ្លាប់បានទៅដើរលេង និងញ៉ាំអីជាមួយគ្នាម្តងម្កាលរហូតមក។ នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៧ ក្រោយពីបានឈ្លោះគ្នាជាមួយសង្សា រួចមកខ្លួនក៏បានជិះម៉ូតូឌុបពីផ្សារច្បារអំពៅសំដៅទៅខុនដូររបស់ឈ្មោះ សិទ្ធ នៅម្តុំដើមថ្កូវ ពេលទៅដល់ក៏អង្គុយលេង និងបាននិយាយប្រាប់ទៅឈ្មោះ សិទ្ធ ដោយប្រាប់ថាខ្លួនបានឈ្លោះគ្នាជាមួយសង្សា ហើយសុំទៅឈ្មោះ សិទ្ធ ថាស្នាក់នៅជាមួយ ២,៣ថ្ងៃ ទំរាំខ្លួនត្រូវរូវជាមួយសង្សាវិញ។ នៅថ្ងៃ ខែ ឆ្នាំដដែលនេះដែរ ខ្លួនបានប្រើប្រាស់គ្រឿងញៀនជាមួយឈ្មោះ សិទ្ធ ។ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៧ ខ្លួនបានប្រើប្រាស់គ្រឿងញៀនតែម្នាក់ឯងក្នុងបន្ទប់ របស់ឈ្មោះ សិទ្ធ ក្នុងបរិមាណគ្រឿងញៀនដែលមានតម្លៃប្រហែលពី ៥ដុល្លា ទៅ ១០ដុល្លា ហើយឈ្មោះ សិទ្ធ ជាអ្នកផ្តល់ឲ្យ។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៧ ឈ្មោះ សិទ្ធ បានបបួលខ្លួនដើលេងជាមួយមិត្តភក្តិរបស់គាត់ពេលត្រឡប់មកដល់បន្ទប់វិញ ក៏បាន



Scanned with CamScanner

ប្រើប្រាស់គ្រឿងញៀនតែម្នាក់ឯង ។ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល ១ថ្ងៃ ឈ្មោះ សិទ្ធ បានបបួលខ្លួន ដោយប្រាប់ថាអាអូនមកជិះម៉ូតូដើរលេងជាមួយហ្នឹងបង ដោយការអផ្សុកផងដែរនោះ ខ្លួនក៏បានទៅជាមួយឈ្មោះសិទ្ធ ពេលនោះឈ្មោះ សិទ្ធ បានជិះម៉ូតូពីខុនដូរមកដល់រង្វង់មូលដើមថ្កូវ ហើយបានបត់តាមមុខសាលាវិទ្យាល័យដើមថ្កូវ សំដៅទៅផ្សារទួលទំពូង ពេលជិះម៉ូតូដល់កំណាត់ផ្លូវពាក់កណ្ដាលពីរង្វង់មូលដើមថ្កូវ និងផ្សារទួលទំពូងនោះ ឈ្មោះ សិទ្ធ បានឈប់ម៉ូតូ ហើយចុះទៅយកកញ្ចប់ថង់ខ្មៅដែលគេទម្លាក់ចោលនៅលើចិញ្ចើមផ្លូវ ដែលមានធូលីពទ្ធ័ជុំវិញ មកដាក់លើម៉ូតូ រួចជិះមកខុនដូរវិញ ពេលនោះខ្លួនឆ្ងល់ដែរប៉ុន្តែមិនហ៊ានសួរទៅឈ្មោះ សិទ្ធ លុះដល់វេលាម៉ោងប្រហែល១៦ ថ្ងៃ ខែ ឆ្នាំដដែល ឈ្មោះ សិទ្ធ បាននិយាយមកខ្លួនថា អាអូនឯងចុះទៅដើរលេងនៅក្រោមទៅកុំឲ្យអផ្សុក បងឲ្យលុយ១០ដុល្លា ហើយបងសុំផ្ញើថង់ ខោ អាវ នេះយកទៅឲ្យគេនៅខាងក្រោមផង គឺមានគេនៅចាំទទួលនៅក្រោម ពេលដេលឈ្មោះ សិទ្ធ ហុចថង់ដាក់សំលៀកបំពាក់ដែលមានលាក់គ្រឿងញៀននៅខាងក្នុង មកឲ្យខ្លួនត្រូវសមត្ថកិច្ចចូលមកឃាត់ខ្លួន ពេលនោះខ្លួនភ័យពេកក៏ទំលាក់ថង់ចោលទៅក្រោម តាមបញ្ជារបស់ឈ្មោះ សិទ្ធ។

បក្ខពួករបស់ខ្លួនមាន៖ ឈ្មោះ សិទ្ធ([redacted] ពិសិដ្ឋ) ភេទប្រុស ត្រូវឃាត់ខ្លួន និង រូបខ្លួន ។

នៅពេលដែលឈ្មោះ សិទ្ធ ថ្លឹង និងច្រកគ្រឿងញៀនក្នុងខុនដូរនោះ គឺរូបខ្លួនបានឃើញ ហើយបាននិយាយថា បងអើយគ្រឿងញៀនអីច្រើនម្ល៉េះ ។

-សាក្សីឈ្មោះ [redacted] ទិសាល បានឆ្លើយថា ខ្លួនជានគរបាលប៉ុស្ដិ៍រដ្ឋបាលបឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ត្រូវបានមេប៉ុស្ដិ៍បញ្ជាឲ្យទៅចូលរួមធ្វើការឆែកឆេរនៅបន្ទប់ខុនដូរលេខ១២៥ បន្ទប់លេខ៥២ ជាមួយកម្លាំងសមត្ថកិច្ចនគរបាលមន្ទីរប្រឆាំងគ្រឿងញៀន ពេលខ្ញុំចុះទៅដល់ខាងមន្ទីរប្រឆាំងគ្រឿងញៀនបានធ្វើការបង្ក្រាបរួចអស់ហើយដោយឃើញឃាត់ខ្លួនបានជនប្រព្រឹត្តចំនួន ៤នាក់ គឺ ប្រុស៣នាក់,ស្រី១នាក់ និងប្រមូលបានវត្ថុតាង ជាគ្រឿងញៀនមួយចំនួន និងឧបករណ៍ប្រើប្រាស់ថ្នាំញៀន។ ចំពោះក្នុងមូលដ្ឋានរបស់ខ្ញុំកន្លងមកដែលមានការគ្រប់គ្រងយាងដឹតដល់មិនដែលឃើញមានតម្រុយចំពោះការប្រព្រឹត្តអំពើល្មើសគ្រឿងញៀនឡើយ ព្រោះថា នៅក្នុងតំបន់នោះគឺជាខុនដូរ មិនឃើញមានសកម្មភាពអ្វីដែលគួរឲ្យកត់សម្គាល់ឡើយ ។

-តាមអំណានលទ្ធផលកោសលវិច្ច័យគ្រឿងញៀនលេខ ១២៣៧៦/១៧ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត ថា៖

ភិនភាគសំណាក៖ សំណាកនៅក្នុងស្រោមសំបុត្រពណ៌សបិទជិត មានហត្ថលេខាគណៈកម្មការ និងស្នាមមេដៃរបស់ឈ្មោះ [redacted] ស្រីណែត គឺ៖

សំណាក ជាប្រភេទក្រាមម្សៅថ្លា ពណ៌ស ទម្ងន់ 0,៦៨៩៦ក្រាម



Scanned with CamScanner

បរិមាណ សំណាកនៅសល់ពីកោសលវិច័យចំនួន ០,២១៤៨ ក្រាម

លទ្ធផល៖ វិជ្ជមាន,វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ។

បរិមាណសារធាតុ មេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់គឺ ៧៤.០៤%

កាសន្និដ្ឋាន៖ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬ ម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៤.០៤% នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងសម្អិត ក្នុងតារាងឧបសម្ពន្ធ ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

-តាមអំណានលទ្ធផលកោសលវិច្ច័យគ្រឿងញៀនលេខ ១២៣៧៧/១៧ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ថា៖

ភិនភាគសំណាក៖ សំណាកនៅក្នុងស្រោមសំបុត្រពណ៌សបិទជិត មានហត្ថលេខាគណៈកម្មការ និងស្នាមមេដៃរបស់ឈ្មោះ [redacted] ពិសិដ្ឋ គឺ៖

សំណាក ជាប្រភេទក្រាមម្សៅថ្លា ពណ៌ស ទម្ងន់ ០.៦៧៦៥ក្រាម

បរិមាណ សំណាកនៅសល់ពីកោសលវិច័យចំនួន ០.១៧៤៤ ក្រាម

លទ្ធផល៖ វិជ្ជមាន,វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ។

បរិមាណសារធាតុ មេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់គឺ ៧៥.៥៥%

កាសន្និដ្ឋាន៖ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬ ម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៥.៥៥% នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងសម្អិត ក្នុងតារាងឧបសម្ពន្ធ ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

-តាមអំណានកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣១៤៤ រ.វ.ត ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៧ មាន៖

១.ស្រោមសំបុត្រពណ៌គគីចំនួន១ សរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមពណ៌សថ្លាទម្ងន់៤៩៥,៥០ក្រាម(បួនរយកៅសិបប្រាំក្បៀសហាសិបក្រាម) ដោយជនសង្ស័យឈ្មោះ [redacted] ពិសិដ្ឋ ផ្ដិតមេដៃទទួលស្គាល់ និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌រួមជាមួយផង។

២.ស្រោមសំបុត្រពណ៌គគីចំនួន១ សរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមពណ៌សថ្លាទម្ងន់៣,៦៣ក្រាម(បីក្បៀសហុកសិបបីក្រាម) ដោយជនសង្ស័យឈ្មោះ [redacted] ស្រីណែត ផ្ដិតមេដៃទទួលស្គាល់ និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌រួមជាមួយផង។

៣.ទូរសព្ទដៃចំនួន២គ្រឿងមាន NOKIAពណ៌ក្រហមលាយខ្មៅចំនួន១ និង ម៉ាក SAMSUNG ពណ៌សចំនួន១ចាស់(មិនដំណើរការ) និងជញ្ជីងថ្លឹងចំនួន២ ។



Scanned with CamScanner

-តាមអំណានកំណត់ហេតុឆែកឆេរ ត្រួតពិនិត្យជាក់ស្តែង ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ របស់មន្ទីរប្រឆាំងគ្រឿងញៀន គណៈកម្មការយើងបានធ្វើការត្រួតពិនិត្យបន្ទប់ខុនដូរលេខ៥២ ផ្ទះខុនដូរលេខ១២៥ ភូមិក្បាលទំនប់សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ យើងបានធ្វើការឆែកឆេររុករកវត្ថុតាង នៅចំពោះមុខឈ្មោះ [redacted] សុភនាត ភេទស្រី ដែលជាម្ចាស់បន្ទប់ជួលខាងលើ ការឆែកឆេរនេះយើងបានរកឃើញ និងចាប់យកសម្ភារៈវត្ថុតាងមាន៖ ម្សៅក្រាមស ចំនួន៨កញ្ចប់ និង សម្ភារៈប្រើប្រាស់មួយចំនួន ។

-តាមអំណានកំណត់ហេតុទទួលស្គាល់សម្ភារៈ និង វត្ថុតាងលេខ ៣៤០ កណហ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ របស់មន្ទីរប្រឆាំងគ្រឿងញៀន ថា បានធ្វើកំណត់ហេតុ ចំពោះមុខជនសង្ស័យដែលបានឃាត់ខ្លួន ត្រូវជាម្ចាស់ សម្ភារៈវត្ថុតាង មានឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ វត្ថុតាងដកហូត សារធាតុប្រភេទមេតំហ្វេតាមីន(ICE) នៅចំពោះមុខរបស់ខ្លួនឈ្មោះ [redacted] ស្រីណែត ។

-តាមអំណានកំណត់ហេតុចាប់យក សម្ភារៈ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ របស់មន្ទីរប្រឆាំងគ្រឿងញៀន ថា បានតាមដានស៊ើបអង្កេតក្នុងករណី អនុវត្តតាមវិធានញុះញង់ឲ្យលក់ដោយខុសច្បាប់នូវសារធាតុញៀន។ ជនសង្ស័យឈ្មោះ [redacted] ស្រីណែត ត្រូវបានរកឃើញទាន់ពេលកំពុងប្រព្រឹត្តបទល្មើសនៅចំណុចខុនដូរលេខ១២៥ ផ្លូវ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឃាត់ខ្លួន ធ្វើការស្ទាបឆែករកឃើញមាន៖ ទូរសព្ទដៃចំនួន ១គ្រឿង ,ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន ១គ្រឿង ។

-តាមអំណានកំណត់ហេតុទទួលស្គាល់សម្ភារៈ និង វត្ថុតាងលេខ ៣៤១ កណហ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ របស់មន្ទីរប្រឆាំងគ្រឿងញៀន ថា បានធ្វើកំណត់ហេតុ ចំពោះមុខជនសង្ស័យដែលបានឃាត់ខ្លួន ត្រូវជាម្ចាស់ សម្ភារៈវត្ថុតាង មានឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ វត្ថុតាងដកហូត សារធាតុប្រភេទមេតំហ្វេតាមីន ទម្ងន់ ៤៩៥,៥០ក្រាម ភិនភាគ នៅចំពោះមុខរបស់ខ្លួនឈ្មោះ [redacted] ស្រីណែត ។

-តាមអំណានកំណត់ហេតុចាប់យក សម្ភារៈ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ របស់មន្ទីរប្រឆាំងគ្រឿងញៀន ថា បានតាមដានស៊ើបអង្កេតក្នុងករណី អនុវត្តតាមវិធានញុះញង់ឲ្យលក់ដោយខុសច្បាប់នូវសារធាតុញៀន។ ជនសង្ស័យឈ្មោះ [redacted] ពិសិដ្ឋ ត្រូវបានរកឃើញទាន់ពេលកំពុងប្រព្រឹត្តបទល្មើសនៅចំណុចខុនដូរលេខ១២៥ ផ្លូវ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឃាត់ខ្លួន ធ្វើការស្ទាបឆែករកឃើញមាន៖ ទូរសព្ទដៃចំនួន ១គ្រឿង ,ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន ១គ្រឿង, ម៉ូតូ ១គ្រឿងម៉ាកស៊ុយសុគី និចពណ៌ក្រហមលាយខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1DG ២០៨៨ លេខតួ CE៤៤F៣០៨៨៥៤ លេខម៉ាស៊ីនAE២-៣០៨៩៣០ ។



Scanned with CamScanner

-តាមអំណានកំណត់ហេតុធ្វើតេស្ត និង វេចខ្ចប់វត្ថុតាង លេខ៩៤៤ កណាហ ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៧ នៅមន្ទីរប្រឆាំងគ្រឿងញៀន ថា បានដំណើរការ ដកសំណាកសារធាតុដែលមានតំរុយថា ជាគ្រឿងញៀនខុសច្បាប់ដែលមាន ម្សៅក្រាមពណ៌សថ្លា ទម្ងន់សរុប ៤៩៥,៥០ក្រាម ជារបស់ឈ្មោះ[redacted]ពិសិដ្ឋ វេចខ្ចប់បញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើតេស្តជំហានដំបូង ប្រភេទស៊ីម៉ុនតេស្ត បានបង្ហាញថា ប្រភេទមេតំហ្វេតាមីន ដែលស្ថិតនៅក្នុងចំណាត់ថ្នាក់សារធាតុហាមឃាត់ក្នុងតារាង២ នៃឧបសម្ព័ន្ធច្បាប់ត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។ បន្ទាប់មកយើងបានដំណើរការវេចខ្ចប់វត្ថុតាងគ្រឿងញៀនខុសច្បាប់ ដែលមានចំនួនដូចខាងលើ នៅចំពោះមុខជនសង្ស័យដាក់បញ្ចូលក្នុងស្រោមសំបុត្រ ប្រភេទក្រដាស់ពណ៌ស មានភិនភាគលឿងទុំ បិទផ្សិតដោយការបង់ស្អិតសថ្លា ជាកិច្ចបញ្ចប់ ។

-តាមអំណានកំណត់ហេតុធ្វើតេស្ត និង វេចខ្ចប់វត្ថុតាង លេខ៩៤៥ កណាហ ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៧ នៅមន្ទីរប្រឆាំងគ្រឿងញៀន ថាបានដំណើរការដកសំណាកសារធាតុដែលមានតំរុយថា ជាគ្រឿងញៀនខុសច្បាប់ដែលមាន ម្សៅក្រាមពណ៌សថ្លា ទម្ងន់សរុប ៣,៦៣ក្រាម ជារបស់ឈ្មោះ [redacted] ស្រីណែត វេចខ្ចប់បញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើតេស្តជំហានដំបូង ប្រភេទស៊ីម៉ុនតេស្ត បានបង្ហាញថា ប្រភេទមេតំហ្វេតាមីន ដែលស្ថិតនៅក្នុងចំណាត់ថ្នាក់សារធាតុហាមឃាត់ក្នុងតារាង២ នៃឧបសម្ព័ន្ធច្បាប់ត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។ បន្ទាប់មកយើងបានដំណើរការវេចខ្ចប់វត្ថុតាងគ្រឿងញៀនខុសច្បាប់ ដែលមានចំនួនដូចខាងលើ នៅចំពោះមុខជនសង្ស័យដាក់បញ្ចូលក្នុងស្រោមសំបុត្រ ប្រភេទក្រដាស់ពណ៌ស មានភិនភាគលឿងទុំ បិទផ្សិតដោយការបង់ស្អិតសថ្លា ជាកិច្ចបញ្ចប់ ។

-តាមអំណានរបាយការណ៍លេខ ៩៤៧ រ.ប.ក ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៧ របស់មន្ទីរប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថា ផ្អែកតាមសកម្មភាពដែលបានប្រព្រឹត្ត និងឆ្លងតាមការស្តាប់ចម្លើយ រួមជាមួយវត្ថុតាងដែលបានចាប់យក មានឈ្មោះ [redacted] ស្រីណែត ភេទស្រី និងឈ្មោះ[redacted] ពិសិដ្ឋ ភេទប្រុស និងឈ្មោះ [redacted]បញ្ញា ភេទប្រុស ពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន កាលពីថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៧ នៅចំណុចខុនដូរលេខ១២៥(បន្ទប់លេខ៥២) ផ្លូវលេខ៤៤បេ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រាកដមែន ។

**សេចក្តីសន្និដ្ឋានថ្មីចសុំរបស់តំណាងអយ្យការ**

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត និងឈ្មោះ[redacted] ពិសិដ្ឋ ,ឈ្មោះ[redacted]បញ្ញា បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តមែន ដែលវត្ថុតាងគ្រឿងញៀនទាំងនេះគឺឈ្មោះ ហុង ជាអ្នកផ្តល់ឲ្យលក់ ដែលចម្លើយនេះស៊ីសង្វាក់ជាមួយចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត ឆ្លើយថាខ្លួនបានទិញគ្រឿងញៀនម្តងក្នុងតម្លៃ ១០ម៉ឺន



Scanned with CamScanner

រៀល ពីឈ្មោះ [redacted] ពិសិដ្ឋ នៅខុនដូរបន្ទប់លេខ៥២ មករំលែកលក់បន្តបានចំណេញម្តង ៦ម៉ឺនរៀល និងបានបញ្ជាទិញពីឈ្មោះ [redacted] ពិសិដ្ឋ ១ជី ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ចំពោះចម្លើយរបស់ឈ្មោះ [redacted] ពិសិដ្ឋ ឆ្លើយថាខ្លួនត្រូវបានឈ្មោះ ហុង បញ្ជូនថ្នាំញៀនមកឲ្យខ្លួនលក់ ពេលលក់អស់ទើបទូទាត់លុយ ដែលការបញ្ជូនថ្នាំញៀននេះតាមរយៈថង់ខ្មៅដាក់ក្បែរសម្រាម រីឯឈ្មោះ [redacted] បញ្ញា ឆ្លើយថាខ្លួនត្រូវបានឈ្មោះ [redacted] ពិសិដ្ឋ ពឹងឲ្យជួយយកថង់ខ្មៅទៅឲ្យគេ ហើយក្នុងរយៈពេលដែលខ្លួនសុំបន្ទប់ខុនដូររបស់ឈ្មោះ [redacted] ពិសិដ្ឋ ស្នាក់អាស្រយ័នៅបណ្ដោះអាសន្ន គឺខ្លួនបានឃើញ [redacted] ពិសិដ្ឋ ច្រកគ្រឿងញៀន។ ហើយកម្លាំងសមត្ថកិច្ច ក៏ចុះបង្ក្រាបធ្វើតាមរយៈវិធានញុះញង់ ធ្វើការឆែកឆេរដល់លំនៅដ្ឋានបន្ទប់ខុនដូរលេខ៥២ រកឃើញក្រាមពណ៌សថ្លាទម្ងន់សរុប ៤៩៥,៥០ក្រាម ជារបស់ឈ្មោះ [redacted] ពិសិដ្ឋ និងម្សៅក្រាមពណ៌សថ្លា ទម្ងន់សរុប ៣,៦៣ក្រាម ជារបស់ឈ្មោះ [redacted] ស្រីណោត បន្ទាប់ពីបានពិនិត្យកំណត់ហេតុធ្វើតេស្ត៍ និងលទ្ធផលកោសលវិច័យព្រមទាំងវត្ថុតាង គឺពិតជាមានអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ស្រីណែត និងឈ្មោះ [redacted] ពិសិដ្ឋ ,ឈ្មោះ [redacted] បញ្ញា កាលពីថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៧ ប្រាកដមែន ដែលអំពើនេះតម្រូវឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ដូចនេះតំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៦០២ អ.យ.ដ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០១៨ ដដែល សូមក្រុមប្រឹក្សាពិចារណា សម្រេចផ្តន្ទាទោសតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស្រីណែត បានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនបានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តមែន ហើយការប្រព្រឹត្តនេះកើតឡើងដោយសារតែ សមត្ថកិច្ចទាក់ទងបានលេខទូរសព្ទ័ពីមិត្តភក្តិរបស់ខ្លួនហើយឲ្យលុយកូនក្តីខ្លួនចំនួន ១២០ដុល្លាអាមេរិក ទៅទិញយកមកលក់ឲ្យ ក្នុងតំម្លៃចំនួន ១០០ដុល្លាអាមេរិក ទង្វើនេះហើយដែលធ្វើឲ្យកូនក្តីខ្លួនកើតនូវការចង់បានដើម្បីបានផលចំណេញយកទៅចិញ្ចឹមកូនតូច១២នាក់នៅក្នុងបន្ទុក ពេលកូនក្តីខ្លួនទិញបានហើយយកមកលក់ឲ្យក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ដែលឆែករកបានថ្នាំញៀននៅក្នុងខ្លួនកូនក្តីមានទម្ងន់ ៣,៦៣ក្រាមតែប៉ុណ្ណោះ ចំណែកឯថ្នាំញៀនទម្ងន់ ៤៩៥,៥០ក្រាមនោះមិនមែនជារបស់កូនក្តីខ្លួនទេព្រោះសមត្ថកិច្ចឆែករកឃើញនៅក្នុងបន្ទប់ខុនដូរលេខ៥២ ។ បន្ទាប់ពីឃាត់ខ្លួនកូនក្តីខ្លួនបានកូនក្តីខ្លួនក៏សហការណ៍ជាមួយសមត្ថកិច្ចដោយនាំទៅដល់បន្ទាប់ខុនដូរលេខ៥២ ដែលធ្វើការបង្ក្រាបបានថ្នាំញៀនមួយចំនួន និងឧបករណ៍ប្រើប្រាស់ និងឃាត់ខ្លួនបានជនប្រព្រឹត្តបន្ថែមទៀត ។ សូមលោកប្រធានក្រុមប្រឹក្សាមេត្តាពិនិត្យ និងពិចារណា លើចម្លើយសារភាព និងការសហការណ៍ជាមួយសមត្ថកិច្ចគ្រប់នីតិវិធី ដែលគប្បីផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនតាមច្បាប់។



Scanned with CamScanner

លោកមេធាវី [redacted] សុខា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] បញ្ញា បានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនបានឆ្លើយសារភាពថា ដោយសារតែស្ថានភាពគ្រួសារក្រីក្រ ម្តាយចាស់ មានការខ្វះខាតជីវភាព ទើបខ្លួនរកស៊ីលក់ថ្នាំញៀន ដើម្បីជីវភាពគ្រួសារ ហើយការប្រព្រឹត្តរបស់កូនក្តីខ្លួនទាំងពីរនាក់គឺ ដោយសារតែមានការអូសទាញពីឈ្មោះ ពៅ ហៅហុង ដែលជាអ្នកយកថ្នាំញៀនឱ្យកូនក្តីខ្លួន។ ដូច្នេះខ្លួនសុំឱ្យក្រុមប្រឹក្សា មេត្តាពិចារណាសម្រេចផ្តន្ទាទោសកម្រិតអប្បបរិមាក្នុងការឱ្យកូនខ្លួនបានកែប្រែកំហុសរបស់ខ្លួន ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្លួនសុំតុលាការសម្រាលទោសដើម្បីបានឆាប់ទៅចិញ្ចឹមបីបាច់ថែរក្សាកូន២នាក់នៅក្នុងបន្ទុក។

-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្លួនសុំតុលាការបន្ធូរបន្ថយទោស ។

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញា បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្លួនសុំតុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយ របស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិភាក្សា និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១- កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល១៦ និង១០នាទី ដោយមានការដឹកនាំសម្របសម្រួលពីលោកព្រះរាជអាជ្ញារង កម្លាំងជំនាញការិយាល័យប្រឆាំងជំនួញគ្រឿងញៀនខុសច្បាប់ នៃមន្ទីរប្រឆាំងគ្រឿងញៀនបានចុះអនុវត្តវិធានប្រគល់ដោយមានការឃ្លាំមើល ឬ ញុះញង់ឱ្យលក់គ្រឿងញៀនខុសច្បាប់ និងបានបង្ក្រាបនៅចំពេលមុខសញ្ញា កំពុងធ្វើសកម្មភាពនៅចំណុច ខុនដូរលេខ១២៥(បន្ទប់៥២) ផ្លូវលេខ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនជនសង្ស័យចំនួន១នាក់ឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ ២៧ឆ្នាំជនជាតិខ្មែរ និងចាប់យកវត្ថុតាង សារធាតុញៀន ប្រភេទមេតំ



Scanned with CamScanner

ហ្វេតាមីន (ICE) ទម្ងន់៣,៦៣ក្រាម ហើយភ្លាមៗនោះ យើងបាននាំខ្លួនជនសង្ស័យរូបនេះទៅចង្អុលបង្ហាញបន្ទប់(បន្ទប់ខុនដូរលេខ៥២) ហើយបានធ្វើការឆែកឆេររកឃើញ សារធាតុញៀនប្រភេទមេតំហ្វេតាមីន (ICE) ទម្ងន់៤៩៥,៥០ក្រាម ដោយឃាត់បានជនសង្ស័យចំនួន ២នាក់មានឈ្មោះ[redacted]ពិសិដ្ឋ ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] បញ្ញា ភេទប្រុស អាយុ ១៧ឆ្នាំជនជាតិខ្មែរ ទៀត ហើយកសាងសំណុំរឿងបញ្ជូនជនសង្ស័យ និងវត្ថុតាង មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ពិតប្រាកដមែន ។

២- នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ស្រីណែត បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តសកម្មភាពជួញដូរថ្នាំញៀនមែន ដោយខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ[redacted]ពិសិដ្ឋ ក្នុងតម្លៃ ១០ម៉ឺនរៀល ហើយយកមកវិលែកលក់បន្តបានចំណេញចំនួន ៦ម៉ឺនរៀល ដែលចម្លើយនេះ បានស៊ីសង្វាក់ជាមួយចម្លើយរបស់ឈ្មោះ[redacted]ពិសិដ្ឋ ដែលបានឆ្លើយថា ខ្លួនធ្លាប់លក់ថ្នាំញៀនឲ្យឈ្មោះ [redacted]ស្រីណែត មែន ដែលស៊ីសង្វាក់ទៅនឹង ចម្លើយឆ្លើយនៅសមត្ថកិច្ច ចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ រួមទាំងវត្ថុចាប់យក ក៏ដូចជារបាយការណ៍របស់មន្ត្រីនគរបាល ព្រមទាំងភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿង អាចបញ្ជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

៣- ជនជាប់ចោទឈ្មោះ[redacted]ពិសិដ្ឋ បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ហុង តាមរយៈទូរសព្ទ ដែលទិញនេះគឺឈ្មោះ ហុង ជាអ្នកបញ្ជូនឲ្យខ្លួនយកមកលក់ នៅពេលលក់អស់ទើបទូទាត់ផ្ញើលុយសងទៅឲ្យឈ្មោះ ហុង ដែលមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ឈ្មោះ[redacted]ស្រីណែត ដែលថាបានទៅទិញថ្នាំញៀន ពីឈ្មោះ [redacted] ពិសិដ្ឋ ដល់ខុនដូរបន្ទប់លេខ៥២ ប្រាកដមែន និងតាមចម្លើយរបស់ឈ្មោះ[redacted] បញ្ញា ដែលឆ្លើយថា ក្នុងពេលដែលខ្លួនស្នាក់នៅក្នុងបន្ទប់ខុនដូររបស់ឈ្មោះ [redacted]ពិសិដ្ឋ គឺធ្លាប់ឃើញឈ្មោះ[redacted]ពិសិដ្ឋ ច្រក និងថ្លឹងថ្នាំញៀនសម្រាប់លក់មែន ដែលចម្លើយទាំងនេះ ស៊ីសង្វាក់ទៅនឹងចម្លើយដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាល និងចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ រួមទាំងវត្ថុចាប់យក ក៏ដូចជារបាយការណ៍របស់មន្ត្រីនគរបាល ព្រមទាំងភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿង ប្រាកដមែន ។

៤- នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted]បញ្ញា បានឆ្លើយបដិសេធថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដែលចម្លើយនេះគ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ព្រោះថា តាមចម្លើយដែលឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរបានឆ្លើយថា ក្នុងអំឡុងពេលដែលខ្លួនកំពុងស្នាក់នៅក្នុងបន្ទប់ខុនដូរគឺ ខ្លួនធ្លាប់ឃើញឈ្មោះ [redacted] ពិសិដ្ឋ ច្រក និងថ្លឹង ថ្នាំញៀន ព្រមទាំងពឹងឲ្យជួយកាន់កញ្ចប់មួយយកទៅឲ្យគេ ដោយទទួលបានប្រាក់ចំនួន ១០ដុល្លាអាមេរិក ពីឈ្មោះ [redacted] ពិសិដ្ឋ ផងដែរ ព្រមទាំងសមត្ថកិច្ចចូលទៅឃាត់ខ្លួនបាននៅក្នុងបន្ទប់ខុនដូរលេខ៥២ រួមទាំងឆែកឆេររកឃើញថ្នាំញៀន នៅក្នុងបន្ទប់នោះផងដែរ តាមរយៈការ



Scanned with CamScanner

ឆ្លើយដោះសាររបស់ជនជាប់ចោទ ពុំបានភស្តុតាងណាមួយដែលបញ្ជាក់ឲ្យតុលាការជឿបានឡើយ ព្រោះចម្លើយដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាល និងចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ រួមទាំងវត្ថុចាប់យក ក៏ដូចជារបាយការណ៍របស់មន្ត្រីនគរបាល ព្រមទាំងភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿង ពិតជាបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] បញ្ញា ពិតជាបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

៥- ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត និងឈ្មោះ [redacted] ពិសិដ្ឋ ជានីតិជន ដែលមានសមត្ថភាពទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ពោលគឺជនជាប់ចោទពុំមានភស្តុតាងណាមកបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

៦- ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ជាអនីតិជន ដែលមានសមត្ថភាពទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ពោលគឺជនជាប់ចោទពុំមានភស្តុតាងណាមកបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

៧- សកម្មភាពរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិត ក្នុងការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់អ្នកដទៃប្រាកដមែន ។

៨- អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ព្រមទាំងសុខភាពស្មារតីរបស់អ្នកដទៃ ។

៩- វត្ថុចាប់យកដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣១៤៤ រ.វ.ត ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៧ មាន៖

ក.ស្រោមសំបុត្រពណ៌គគីចំនួន១ សរសេថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមពណ៌ស ដោយជនសង្ស័យឈ្មោះ [redacted] ពិសិដ្ឋ ផ្តិតថ្នាទម្ងន់៤៩៥,៥០ក្រាម(បួនរយកៅសិបប្រាំក្បៀសហាសិបក្រាម) មេដៃទទួលស្គាល់ និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌រួមជាមួយផង។

ខ.ស្រោមសំបុត្រពណ៌គគីចំនួន១ សរសេថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមពណ៌ស ថ្នាទម្ងន់៣,៦៣ក្រាម(បីក្បៀសហុកសិបបីក្រាម) ដោយជនសង្ស័យឈ្មោះ [redacted] ស្រីណែត ផ្តិតមេដៃទទួលស្គាល់ និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌រួមជាមួយផង។

គ.ទូរសព្ទដៃចំនួន២គ្រឿងមាន NOKIAពណ៌ក្រហមលាយខ្មៅចំនួន១ និង ម៉ាក SAMSUNG ពណ៌សចំនួន១ចាស់(មិនដំណើរការ) និងជញ្ជីងថ្លឹងចំនួន២ គប្បីរឹបអូស ។

១០- ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ជាអនីតិជនអាយុ ១៧ឆ្នាំ ដែលគប្បីតុលាការពិចារណា ទៅលើមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

១១-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ ២៧ឆ្នាំជនជាតិខ្មែរ សញ្ជាតិខ្មែរ និង ឈ្មោះ [redacted]ពិសិដ្ឋ ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងឈ្មោះ [redacted]បញ្ញា ភេទប្រុស អាយុ ១៧ឆ្នាំជនជាតិខ្មែរ សញ្ជាតិខ្មែរ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចខុនដូរលេខ១២៥(បន្ទប់លេខ៥២) ផ្លូវលេខ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## <u>ហេតុដូច្នេះសម្រេច</u>

**១-ផ្តន្ទាទោស**

ក. ឈ្មោះ[redacted] **ស្រីណែត** ហៅ ដា ភេទស្រី អាយុ ២៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២៣ (ម្ភៃបី) ឆ្នាំ និង ពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល

ខ. ឈ្មោះ [redacted] **ពិសិដ្ឋ** ហៅ សិដ្ឋ ភេទប្រុស អាយុ ២៣ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២៣ (ម្ភៃបី) ឆ្នាំ និង ពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល

គ.ឈ្មោះ [redacted] **បញ្ញា** ហៅ ឡា រី ប៊ិះ ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់២០ (ម្ភៃ) ឆ្នាំ និង ពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ (ហាសិបលាន) រៀល

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចខុនដូរលេខ១២៥ (បន្ទប់លេខ៥២) ផ្លូវលេខ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១៧ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

២- **រឹបអូសវត្ថុចាប់យក** តាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺ៖

ក. ស្រោមសំបុត្រពណ៌គគីចំនួន១ សរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមពណ៌ស ផ្ទុកទម្ងន់៤៩៥,៥០ក្រាម(បួនរយកៅសិបប្រាំក្បៀសហាសិបក្រាម) ដោយជនសង្ស័យឈ្មោ[redacted]ិសិដ្ឋ ផ្តិតមេដៃទទួលស្គាល់ និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌រួមជាមួយផង និង

ខ. ស្រោមសំបុត្រពណ៌គគីចំនួន១ សរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមពណ៌ស ផ្ទុកទម្ងន់៣,៦៣ក្រាម(បីក្បៀសហុកសិបបីក្រាម) ដោយជនសង្ស័យឈ្មោះ[redacted] ស្រីណែត ផ្តិតមេដៃទទួលស្គាល់ និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌រួមជាមួយផង និង

គ. ទូរសព្ទដៃចំនួន២គ្រឿងមាន NOKIAពណ៌ក្រហមលាយខ្មៅចំនួន១ និង ម៉ាក SAMSUNG ពណ៌សចំនួន១ចាស់(មិនដំណើរការ) និងជញ្ជីងថ្លឹងចំនួន២ ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted]ស្រីណែត, ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted]បញ្ញា , មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៨ ។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៦កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៨

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner